FIRST 5 CALIFORNIA

នៅឆ្នាំដំបូង

ការរៀនសូត្រ ចាប់ផ្តើមតាំងពីក្មេងវ័យ

សង្ឃឹមចង់បានអ្វីខ្លះពីកូនង៉ែតរបស់អ្នក នៅក្នុងរយៈពេលឆ្នាំទីមួយ និងរបៀបដែលអ្នកអាចជួយក្មេងម្នាក់ឲ្យធំធាត់ និងរៀនសូត្រ

កូនង៉ែតទាំងឡាយនឹងរៀនត្រួតត្រាតខ្លួន ៖ ទៅលើខ្លួនរបស់គេ ។ កូនង៉ែតទាំងពួងគួរតែចេះ ៖

- ទប់ក្បាលរបស់គេ
- ក្រឡាប់
- អង្គុយត្រង់ខ្លួន
- លូនវារ
- ក្រោកឈរត្រង់ខ្លួន
- នៅពេលខ្លះក៏ដើរ

កូនង៉ែតទាំងឡាយនឹងចាប់ផ្តើមរៀន នៅពេលគេបែកចេញពីអ្នកឯទៀត ។ កូនង៉ែតនឹង :

- មើលដៃនិងម្រាមជើងរបស់គេ ហើយលេងវា ។
- យំនៅពេលឱ្យពុកម្តាយរបស់គេបានចាកចេញ ។
- រៀនស្គាល់ឈ្មោះរបស់គេ ។

កូនង៉ែតទាំងឡាយរៀននិយាយ ។

- ជាដំបូង កូនង៉ែតទាំងឡាយក៏យំ ហើយមានសូរ ខ្សឹកខ្សួលនៅបំពង់ក ។
- ក្រោយមក គេក៏និយាយកកែកករ ហើយក៏ថា “ម៉ាក់” និង “ប៉ា” ។
- គេបញ្ចេញសំឡេងយ៉ាងច្រើន ។
- គេចាប់ផ្តើមហៅឈ្មោះរបស់ផ្សេងៗ និងមនុស្សដែលគេស្គាល់ ។

កូនង៉ែតទាំងឡាយចាប់ផ្តើមលេងល្បែងផ្សេងៗ ។ កូនង៉ែតទាំងពួងគឺអាច :

- លេងជាមួយនឹងដៃរបស់គេ ។
- បង្ហាញពីការចូលចិត្តនឹងប្រដាប់លេង ។
- ចាប់ផ្តើមចូលចិត្តលេងល្បែង “ការដាក់ចូលក្នុង និងការយកចេញមកក្រៅ” ។
- ចាប់ផ្តើមចូលចិត្តវាយប្រដាប់លេងមួយទៅនឹងប្រដាប់លេងមួយទៀត ។
- បីកូនក្រមុំលេង ឬវត្ថុអ្វីដែលមានញាត់សំឡី ។

កូនង៉ែតទាំងឡាយនឹងចាប់ផ្តើមមានទំនាក់ទំនងទៅមនុស្សផ្សេងៗទៀត ។

- ជាដំបូង កូនង៉ែតទាំងឡាយនឹងមានទំនាក់ទំនង ទៅអ្នក និងមនុស្សពេញវ័យផ្សេងទៀត ។
- ក្រោយមក កូនង៉ែតទាំងឡាយនឹងសំគាល់កូនង៉ែតឯទៀតៗ ។

ប្រយោជន៍ឲ្យធំធាត់ កូនង៉ែតទាំងឡាយត្រូវការ :

- នរណាម្នាក់ដែលស្រឡាញ់គេ ហើយជួយគេយ៉ាងរហ័សនៅពេលគេយំ ។
- នរណាម្នាក់ដែលបានស្គាល់គេ ។
- នរណាម្នាក់ដែលរក្សាថែគេឲ្យមានក្តីសុខ និងរក្សាឲ្យគេមានការកក់ក្តៅ ។
- មានឱកាសទៅណាមកណា និងមានឱកាសធ្វើការអ្វីថ្មីៗ ។

កូនង៉ែតវាត្រូវការ :

- របស់អ្វីដែលសុខដើម្បីសំឡឹងមើល ចាប់យក វាយគោះ ស្តាបអង្អែល និង ដើម្បីប្រម្សៀល ។
- មានកន្លែងផុតពីគ្រោះថ្នាក់សំរាប់លេង ។
- មានឱកាសដើម្បីស្តាប់ការនិយាយ និងធ្វើសំឡេង ។

ផ្តល់សេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់ដល់ក្មេងៗ ។

- អានស្បៃវ៉ៅ ច្រៀងចំរៀង និងនិយាយជាមួយកូនៗ រាល់ថ្ងៃ ។
- សំរបតាមសេចក្តីត្រូវការរបស់កូនៗ ដោយមិនយឺតយូរណ៏ ។
- ការពារកូនង៉ែតរបស់អ្នក ឲ្យបានញឹកញាប់ ។
- ធ្លើយសំរែកយំរបស់កូនង៉ែត ហើយធ្លើយសំណួរកូនរបស់អ្នក ។

ធ្វើឲ្យកន្លែងសំរាប់ក្មេងៗលេង ប្រកបដោយក្តីសុខសាន្ត ។

- ផ្តល់ពេលវេលាឲ្យកូនៗរត់ ហក់លោត និងរាំរែក ។
- បណ្តោយកូនៗឲ្យគូរគំនូរ ឬលេងជាមួយដុំឈើកង់ៗ និងបន្ទះក្រដាសរឹងៗ ជំរៀបជារូបផ្សេងៗ ។
- ផ្តល់ឱកាសឲ្យកូនៗ ដើម្បីធ្វើការអ្វីមួយដោយខ្លួនឯង ។

វាក៏ជាការល្អផងដែរ ដើម្បី :

- ស្បៃបចំពេលវេលា ដើម្បីលេងជាមួយក្មេងៗឯទៀត ។
- អនុញ្ញាតឲ្យកូនៗមានការជ្រើសរើសខ្លះ ។

©2003 First 5 California